ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៩៧៥ គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ១១ ឆ្នាំ២០១៦

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**តាមរយៈ** ÷ **ឯកឧត្តមរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**កម្មវត្ថុ** ÷ សំណើសុំបង្កើតក្រុមការងារអន្តរ**ក្រសួង** សិក្សាអំពីស្ថានភាព និងកិច្ចដំណើរការនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

**យោង** ÷ – សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ១០៥១សជណចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០១៦ អនុញ្ញាតឱ្យគ.ជ.អ.ប ដឹកនាំសម្របសម្រួលរៀបចំសិក្សាអំពីស្ថានភាពនៃការគ្រប់គ្រង និងការអនុវត្តការងាររបស់ការិយាល័យជំនាញរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ

– ចំណារឯកភាពរបស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធាន គ.ជ.អ.ប ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១៦លើសំណើសុំគោលការណ៍រៀបចំក្រុមការងារអន្តរក្រសួងសិក្សាអំពីស្ថានភាព និងកិច្ចដំណើរការនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ

– លិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈស្តីពីការចាត់តាំងមន្ត្រីជាន់ខ្ពស់ចំនួន០២រូបនៃក្រសួងនីមួយៗជាសមាជិកក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីស្ថានភាព និងកិច្ចដំណើរការនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំសេចក្តីព្រាងស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីធ្វើការសិក្សា ស្រាវជ្រាវអំពីស្ថានភាព និងកិច្ចដំណើរការនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងលើកអនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័ននានា និងរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេចលើលទ្ធភាពនៃការផ្ទេរមុខងារ ធនធាន និងការផ្ទេរការិយាល័យជំនាញទាំងនោះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ក្រុមការងារអន្តរក្រសួងនេះ នឹងត្រូវដឹកនាំ និងសម្របសម្រួល ដោយលេខាធិការដ្ឋានគ.ជ.អ.ប. និងមានសមាសភាពមកពីតំណាងនៃកម្មវិធីកំណែទម្រង់ទាំងបី គឺកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងនាយកដ្ឋានមួយចំនួននៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ រួមមាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានមុខងារនិងធនធាន និងនាយកដ្ឋានកិច្ចការក្រុង ស្រុក ឃុំ សង្កាត់ ដូចមានភ្ជាប់ជូនមកជាមួយ។

អាស្រ័យហេតុនេះ សូម**សម្តេចក្រឡាហោម** មេត្តាពិនិត្យ សម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេច** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**អនុប្រធានប្រតិបត្តិលេខាធិការដ្ឋាន គ.ជ.អ.ប**